**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣៥២
ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៩
**សាលដីកា**
លេខៈ ២៥៨
ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............ ជាចៅក្រម
៣-លោក ............... ជាចៅក្រម
៤-លោក ............... ជាចៅក្រមរបាយការណ៍
៥-លោក ................ ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ................

**តំណាងមហាអយ្យការ**
-ឯកឧត្តម ..............ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកានខ៤៨២ ចុះថ្ងៃទី២២ខែកក្កដាឆ្នាំ១៩៩៩នៃសំណុំរឿងរដ្ឋប្បវេណីលេខ២២៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ អឈ ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរមុខរបរ ធ្វើស្រែ ទីលំនៅភូមិភ្នំឱល ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ។ឪពុកឈ្មោះអេង ស (ស) ម្តាយឈ្មោះនុត ណែម (ស) ប្រពន្ធឈ្មោះបាន អៀង ។ ជាតំណាងឱ្យប្រជាជនទាំង ៧ គ្រួសារ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ សសឈ ភេទស្រី អាយុ៥៣ឆ្នា ជាផខ្មែរមុខរបរលក់ដូរទីលំនៅ ភូមិជើងធ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះ គឹម សុង (រ)ម្តាយឈ្មោះ គឹម លីវ (រ)ប្តីឈ្មោះ យូ ឆាយ ។

**កម្មវត្ថុបណ្តឹង** ប្តឹងសុំគ្រប់គ្រងលំនៅដ្ឋានទំហំ ៨៤៤ម$^{២}$ និង សុំឱ្យប្រជាជនរុះរើផ្ទះចេញពីដី

បានឃើញបណ្តឹងសាទុក្ខលេខ២៩១ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩ របស់លោក អឈ (តំណាងឱ្យប្រជាជន) បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេច នៃសាលដីកាលេខ៤៨២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៥២ ចុះថ្ងៃទី១០ ខែវិច្ឆិកាឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៦-១០-៩៨ របស់ឈ្មោះសសឈ ប្តឹងសុំសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋានទំហំ ៨៤៤ម² និងសុំឱ្យប្រជាជនរុះរើផ្ទះចេញពីកើតហេតុ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ០២(ក) ចុះថ្ងៃទី០៦ ខែមករាឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ចំពោះមុខដើមចោទ និងចុងចម្លើយ ដែលមានខ្លឹមសារ នៃសេចក្តី សម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះសសឈ ចុះថ្ងៃទី០៦-១០-១៩៩៨ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទោស់នឹងគតិច្បាប់ "មានសាលក្រមស្ថាពររួចហើយ" ។

២-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧០០០រៀល ដែលដើមចោទនបង់ទុករួចហើយ។ ចំពោះ ប្រាក់ពន្ធសមាមាត្រគ្មាន ។

៣- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខដើមចោទ និងចុងចម្លើយ ។ ភាគីណាមិនសុខចិត្តនឹងសាលក្រមនេះ មានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លខ១៥ ចុះថ្ងៃទី០២ ខែមិនា ឆ្នាំ១៩៩៩ របស់អ្នកស្រីសសឈ បានប្តឹងមិនសុខចិត្តនឹងសាលក្រមលេខ០២(ក) ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៤៨២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ចំពោះមុខគូក្តី ដែលមានខ្លឹមសារ នៃ សេចក្តីសំរេចដូចតទៅ :

១. ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០២-០៣-១៩៩៩ របស់នាង សសឈ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២. បដិសេធសាលក្រមរដ្ឋប្បវេណីលេខ០២(ក) ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការខេត្តកំពង់ចាម ចោលជាអសារបង់ ។

៣- ប្រគល់ដីទាស់ ដែលស្ថិតនៅខាងមុខទល់ជាប់ដីកម្មសិទ្ធិរបស់នាងសសឈ ឱ្យនាង សសឈ គ្រប់គ្រងចាប់ពីពេលដែលសាលដីកានេះ ចូលជាស្ថាពរ តែហាមមិនឱ្យសាងសង់សំណង់ស្ថិតស្ថេរនានាលើដីនេះឡើយ ហើយត្រូវប្រគល់ឱ្យរដ្ឋដោយគ្មានលក្ខខ័ណ្ឌនៅពេលដែលរដ្ឋត្រូវការ ។

៤- បង្គាប់ឱ្យចុងចម្លើយឈ្មោះ អឈ ជាតំណាងផ្ទេរសិទ្ធិព្រមទាំងឈ្មោះប៊ិន , ធៃ លាង ផល អ៊ិន ភួង សារឿន និង អេង រុះរើសំណង់ផ្ទះលំនៅរបស់ខ្លួនចេញពីដី ទាស់ចាប់ពីពេលដែលសាលដីកានេះចូលជាស្ថាពរតទៅ ។

៥- កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ និងឱ្យចុងចម្លើយសងវិញ(បង់ពន្ធសមាមាត្រគ្មាន) ។

៦- សាលដីកានេះជំនុំជំរះនៅថ្ងៃទី២០-០៧-១៩៩៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២-០៧-១៩៩៩ ចំពោះមុខគូក្តី សម្រេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ២៩១ ចុះថ្ងៃទី១០ខែសីហា ឆ្នាំ១៩៩៩ របស់លោក អេង ឈួន (តំណាងឱ្យប្រជាជន) បានប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៤៨២ ចុះថ្ងៃទី២២ ខែ កក្កដា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី០៤-០១-២០០០ របស់ឈ្មោះ អឈ

បានឃើញសារណាតប ចុះថ្ងៃទី២៧-០១-២០០០ របស់ឈ្មោះ សសឈ

បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខរបស់ចុងចម្លើយ ធ្វើឡើងស្ថិតនៅក្នុងកំណត់ច្បាប់គ ប្បីលើកយកមកពិនិត្យពិចារណា ។

-ការសម្រេចសេចក្តី របស់សាលាឧទ្ធរណ៍ គឺខុសឆ្គងនឹង គតិច្បាប់ ។

ហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ សម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ អឈ ជាចុងចម្លើយ និងជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថាៈ នៅសាលាឧទ្ធរណ៍ កាត់មិនសមស្របនឹង៧គ្រួសារទេ ពេលនេះខ្លួនសូមបកស្រាយការមិនសមស្របនេះ ដោយដីនេះ៧គ្រួសាររស់នៅតាំងពីឆ្នាំ៧៩មកម្លេះ រដ្ឋអំណាច ក៏ទទួលស្គាល់ ឯដើមចោទគាត់ទិញគេនៅឆ្នាំ៩៣ ហើយបានធ្វើប្លង់ថាដីទំនាស់នេះជារបស់គាត់ ហើយក៏បានដេញខ្លួនចេញ ពេលនោះខេត្តក៏បានបដិសេធចោលការប្តឹងនេះទៅហើយ ក្រោយមកដើមចោទប្តឹង ៧ គ្រួសារម្តងទៀត តែផុលាការនៅតែបដិសេធ ហើយសាលក្រមក៏ចូលជាស្ថាពររួចទៅហើយ គេប្តឹងមកសាលាឧទ្ធរណ៍ទៀត ការធ្វើផ្ទះនៅលើខ្លួនកាន់កាប់ពីឆ្នាំ៧៩មក ធ្វើផ្ទះគ្រាន់តែរស់នៅបានប៉ុណ្ណោះសាលាឧទ្ធរណ៍សម្រេចខុសច្បាប់ ទើបខ្លួនប្តឹងមកតុលាការកំពូល ។

បានស្តាប់ចម្លើយរបស់ឈ្មោះសសឈ ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថាៈ ៧គ្រួសារនេះមុនធ្វើថ្នល់ គេរុះម្តងហើយ គេសង់ម្តងទៀតខ្លួនមិនសុខចិត្តទើបប្តឹងម្តងទៀត ៧គ្រួសារនេះសង់ផ្ទះលើដីចំណីថ្នល់ តែកម្មសិទ្ធិរបស់ខ្លួនឆ្នាំ៨៦-៨៧ មកសង់ផ្ទះចុះទៅខាងក្រោម ដំបូងធ្វើលើចំណីថ្នល់ ក្រោយមកសង់ចុះទៅក្រោម ធ្វើឱ្យប៉ះពាល់ដល់ ដីកម្មសិទ្ធិរបស់ខ្លួន សូម

មើលចុះមានប្លង់រួចហើយ ខ្លួនមិនបានប្តឹងឧទ្ធរណ៍ ដោយរដ្ឋដេញអស់ហើយ ក្រោយផុតឧទ្ធរណ៍ទៅ គេសង់ឡើងវិញ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២៩១ ចុះថ្ងៃទី១០-០៨-៩៩ របស់លោកអឈ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ លើកយករឿងក្តីនេះ មកដោះស្រាយគឺជាការ ភ័ក្តប្រឡំពីព្រោះថា រឿងក្តីនេះ ដែលមានកម្មវត្ថុបណ្តឹង និងដើមចោទ និង ចុងចម្លើយ ដែលត្រូវបានតុលាការខេត្តកំពង់ចាម លើកយកមកដោះស្រាយម្តងមកហើយ តាមអំណាចសាលក្រមរដ្ឋប្បវេណីលេខ០២ ចុះថ្ងៃទី០៣-០១-៩៥ ហើយដែលត្រូវចូលជាស្ថាពរ តាំងពីថ្ងៃទី០៣-០៣-៩៥ ម្លេះហើយក៏ពុំមានបណ្តឹងពីអាជ្ញាធរដែនដី ឬពីក្រសួងជំនាញដែរ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៤៨២ ចុះថ្ងៃទី២២-០៧-៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ២៩១ចុះថ្ងៃទី១០-០៨-៩៩ របស់លោកអេងឈួន តំណាងឲ្យប្រជាជន០៦គ្រួសារ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-អ្នកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៤៨២ ចុះថ្ងៃទី២២-០៧-៩៩ របស់សាលា ឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកអឈ បានបង់ទុកជាមុនគឺៈ

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន៩.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រី សសឈ សងប្រាក់ចំនួន១៩.០០០៛ នេះទៅឱ្យលោក អឈ វិញ ។

៤. សាលដីការនេះ ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៩-១២-២០០០។